# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ : ០០៦/២៦ ក.ប/ស.ជ.ណ.ប.ល

## សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ពាក្យស្នើសុំវគ្គបណ្តុះបណ្តាលរយៈពេលខ្លី (១សប្តាហ៍) ឆ្នាំ២០២៦

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់អង្គភាពបណ្តុះបណ្តាលសាធារណៈ ឯកជន សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះបញ្ជិកានៅក្រសួង ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ឱ្យបានជ្រាបថា ក្នុងឆ្នាំ២០២៦នេះ ក្រសួងបានអនុវត្តថវិកាសមិទ្ធកម្ម ដែលក្នុងនោះមានកម្មវិធីមួយឈ្មោះថា "ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ" ដោយផ្តោតលើការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈជូនដល់សិក្ខាកាម ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារការងារទាំងក្នុងស្រុក និងក្រៅស្រុក ប្រកបដោយចំណេះដឹង សមត្ថភាពជំនាញ ឥរិយាបថការងារ សីលធម៌វិជ្ជាជីវៈ ផលិតភាពខ្ពស់ និងមានលក្ខណៈប្រកួតប្រជែង សម្រាប់ការងារពេញមួយជីវិត។ តាមរយៈកម្មវិធីនេះ ក្រសួងនឹងផ្តល់ថវិកាសម្រាប់វគ្គបណ្តុះបណ្តាលរយៈពេលខ្លី (១សប្តាហ៍) ឆ្នាំ២០២៦ ជូនដល់អង្គភាពបណ្តុះបណ្តាលដែលបានចុះបញ្ជិកា មានបទពិសោធ និងលក្ខណសម្បត្តិគ្រប់គ្រាន់ ឆ្លើយតបតាមលក្ខណៈវិនិច្ឆ័យ ដែលបានកំណត់ដោយក្រសួង ដើម្បីបណ្តុះបណ្តាលដល់ក្រុមគោលដៅរួមមាន ជនទីទ័លក្រ ស្ត្រីមេម៉ាយ ក្មេងកំព្រា សិស្សបោះបង់ការសិក្សា ជនពិការ និងជនបាត់បង់ឱកាសការងារ។ វគ្គបណ្តុះបណ្តាលនេះ មានរយៈពេលមួយសប្តាហ៍ លើផ្នែកបច្ចេកទេសកសិកម្ម និងការកែច្នៃផលិតផលជាដើម។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមអង្គភាពបណ្តុះបណ្តាលសាធារណៈ ឯកជន សមាគម និងអង្គការមិនមែនរដ្ឋាភិបាល អញ្ជើញមកទាក់ទង និងដាក់ពាក្យស្នើសុំវគ្គបណ្តុះបណ្តាលរយៈពេលខ្លី (១សប្តាហ៍) ឆ្នាំ២០២៦ នៅនាយកដ្ឋានបណ្តុះបណ្តាលនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ស្ថិតនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានអាសយដ្ឋាន ផ្លូវសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃ ពុធ ៧កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៦ រៀងរាល់ម៉ោងធ្វើការ ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ចាប់ពីម៉ោង ៧:០០នាទីព្រឹក ដល់ម៉ោង ១៧:៣០នាទីល្ងាច លេខទូរសព្ទទំនាក់ទំនង ០១២ ៧៥៣ ៦៧៨/០៩៦ ៣៥៥ ០១៦៥។

ថ្ងៃ ចន្ទ ៧កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៦

រដ្ឋមន្ត្រី

ហេង សួរ

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
- គ្រឹះស្ថាន អ.ប.វ. ក្រោមឱវាទ "ដើម្បីជួយផ្សព្វផ្សាយ"
- ឯកសារ កាលប្បវត្តិ